# ទេសន្តរប្រវេសន៍ ការភៀសខ្លួន និងអំពើជួញដូរមនុស្ស

## សាវតា

អំពើជួញដូរមនុស្សបន្តស្ថិតនៅក្នុងគំរូនៃការធ្វើទេសន្តរប្រវេសន៍កាន់តែទូលំទូលាយក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។ តំបន់នេះមើលឃើញការធ្វើទេសន្តរប្រវេសន៍ការងារយ៉ាងទូលំទូលាយនិងជាញឹកញាប់នៅក្នុងតំបន់ដែលជំរុញដោយកំណើនសេដ្ឋកិច្ច និងទំនាក់ទំនងគ្នាទៅវិញទៅមកកាន់តែស៊ីជម្រៅនិងឆ្លុះបញ្ចាំងពីភាពខុសគ្នានៃប្រជាសាស្ត្រនិងសេដ្ឋកិច្ចសង្គម។ ក្នុងឆ្នាំ ២០១៧ ជនទេសន្តរប្រវេសក៍ចំនួន ១០៦ លាននាក់មានដើមកំណើតនៅអាស៊ីប៉ាស៊ីហ្វិក ហើយការផ្ទេរប្រាក់ទៅកាន់តំបន់នេះមានចំនួនសរុប ២៥៦ពាន់លានដុល្លារអាមេរិក ខណៈពលករទេសន្តរប្រវេសក៍បានចូលរួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍនៅក្នុងប្រទេសដើមទូទាំងតំបន់។ តំបន់អាស៊ីក៏ជាតំបន់ដែលងាយរងគ្រោះថ្នាក់បំផុតនៅលើពិភពលោក។ នៅឆ្នាំ ២០១៧ គ្រោះមហន្តរាយនៅតំបន់អាស៊ីប៉ាស៊ីហ្វិក បានបង្កឱ្យមានការភៀសខ្លួនរបស់ប្រជាជនចំនួន ៨,៦ លាននាក់ឬស្មើនឹង ៤៦ ភាគរយនៃចំនួនប្រជាជនសរុបទូទាំងពិភពលោក។ ជម្លោះប្រដាប់អាវុធ បានបង្កឱ្យមានការភៀសខ្លួនរបស់ប្រជាជនបន្ថែមចំនួន ៧០៥.០០០ នាក់។

ការធ្វើទេសន្តរប្រវេសន៍និងការភៀសខ្លួន ធ្វើឱ្យមានបញ្ហាស្មុគស្មាញដល់ការអភិវឌ្ឍដែលទាក់ទងនឹង៖ អភិបាលកិច្ចនិងសិទ្ធិមនុស្ស កំណើនសេដ្ឋកិច្ចនិងជីវភាពក្រីក្រ នគរូបនីយកម្ម ការប្រែប្រួលអាកាសធាតុនិងគ្រោះមហន្តរាយ ជម្លោះនិងវប្បធម៌ហិង្សា យេនឌ័រនិងយុវជន និងការថែរក្សាសន្តិភាព។ គំរូនៃការធ្វើទេសន្តរប្រវេសន៍នៅអាស៊ីប៉ាស៊ីហ្វិកត្រូវបានលាយបញ្ចូលគ្នាកាន់តែខ្លាំងឡើងរួមមានបន្លាស់ទីស្ម័គ្រចិត្តនិងបង្ខំឱ្យមានកម្រិតផ្សេងៗ។ ដូចនេះ ការធ្វើទេសន្តរប្រវេសន៍និងការភៀសខ្លួន ទាមទារឱ្យមានការឆ្លើយតបជាពហុជំនាញ និងពហុភាគី។

## ការរៀបចំអភិក្រមសម្រាប់ការធ្វើទេសន្តរប្រវេសន៍និងការភៀសខ្លួនរបស់ UNDP

**UNDP** រៀបចំអភិក្រមគ្រប់ជ្រុងជ្រោយសម្រាប់ការធ្វើទេសន្តប្រវេសន៍និងការភៀសខ្លួន និងធ្វើការឆ្ពោះទៅកាន់លទ្ធផលដូចខាងក្រោម៖ វិភាគទានរបស់ជនទេសន្តប្រវេសក៍/ជនភៀសខ្លួននិងអ្នកត្រលប់មកវិញ ចូលរួមក្នុងការអភិវឌ្ឍប្រកបដោយចីរភាពជាអតិបរមា។

ការអនុវត្តត្រូវអនុលោមតាមផ្នែកចំនួន៥ ដូចខាងក្រោម៖

1. ធានានូវការធ្វើទេសន្តប្រវេសន៍គឺជាជម្រើសមួយជាជាងភាពចាំបាច់គាំទ្រជម្រើសផ្សេងៗ ដែលត្រូវការ និងបង្កើតប្រព័ន្ធប្រកាសអាសន្នជាមុននិងកាត់បន្ថយព្រឹត្តិការណ៍ភៀសខ្លួន៖ សង្កត់ធ្ងន់ទៅលើការប្រើប្រាស់ទិន្នន័យដើម្បីវិភាគលំហូរនៃការធ្វើទេសន្តប្រវេសន៍ និងការភៀសខ្លួន ការផ្លាស់ប្តូរឬសគល់និងផលប្រយោជន៍។ យើងធ្វើការជាមួយដៃគូដើម្បីយល់កាន់តែប្រសើរ លើកកម្ពស់ និងអនុវត្តការឆ្លើយតបប្រកបដោយភាពសមស្រប។
2. ផ្តល់ភាពអង់អាចដល់ជនទេសន្តប្រវេសក៍និងសហគមន៍និងប្រទេសដើមនានាដែលជួយសម្រួលដល់ភាពស្អិតរមួតនៃការធ្វើសមាហរណកម្មនិងសង្គម៖ ការចូលរួមរបស់ជនទេសន្តប្រវេសក៍និងជនភៀសខ្លួន សហគមន៍និងរដ្ឋាភិបាលនៅប្រទេសដើមថ្នាក់មូលដ្ឋាននិងថ្នាក់ជាតិ ដើម្បីបង្កើនភាពស្អិតរមួតក្នុងសង្គមនិងការគោរពរវាងសហគមន៍មានដើមកំណើតខុសៗគ្នា។
3. ពង្រឹងបណ្តាញសម្រាប់សហគមន៍របស់ជនទេសន្តប្រវេសក៍និងជនភៀសខ្លួន ទាំងក្នុងតំបន់និងពីតំបន់ណាមួយ ដើម្បីចូលរួមផ្តល់វិភាគទានក្នុងការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងប្រទេសកំណើតរបស់ពួកគេ៖ វិភាគទានវិជ្ជមានរបស់សហគមន៍របស់ជនទេសន្តប្រវេសក៍និងជនភៀសខ្លួន តាមរយៈការផ្សព្វផ្សាយនិងការចូលរួម។
4. បង្កើតភាពធន់របស់ជនទេសន្តប្រវេសក៍និងជនភៀសខ្លួន ចំពោះភាពងាយរងគ្រោះជាច្រើនរួមមានអំពើជួញដូរមនុស្ស៖ អនុវត្តកម្មវិធីបង្ការទប់ស្កាត់ដើម្បីបង្កើតភាពធន់ រួមទាំងអំពើជួញដូរមនុស្ស។ សហគមន៍ដើមនឹងត្រូវចូលរួមដើម្បីកាត់បន្ថយផលវិបាកនៃជម្លោះ គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុទៅលើជនភៀសខ្លួន។
5. គាំទ្រការធ្វើសមាហរណកម្ម ឬ ការធ្វើសមាហរណកម្មឡើងវិញដល់ជនទេសន្តប្រវេសន៍ និងជនភៀសខ្លួន។ ជួយរៀបចំសេវាជាច្រើនដោយសហការជាមួយដៃគូសម្រាប់ការធ្វើសមាហរណកម្ម/ការធ្វើសមាហរណកម្មឡើងវិញដោយជោគជ័យ ស្របតាមតម្រូវការរបស់ពួកគេក្នុងវដ្តនៃការធ្វើទេសន្តប្រវេសន៍ជោគជ័យ និងតម្រូវការរបស់ជនភៀសខ្លួនត្រលប់មកវិញ បន្ទាប់ពីមានជម្លោះ ឬ គ្រោះមហន្តរាយ។

ការងារដែលអង្គការ UN-ACT បានអនុវត្តសមស្របនៅក្នុងក្របខ័ណ្ឌនេះនៅក្នុងផ្នែកផ្សេងគ្នាភាគច្រើននៅក្នុង**ផ្នែកទី៤និងនិងផ្នែកទី៥** ៖ ការបង្កើតភាពធន់របស់ជនទេសន្តរប្រវេសក៍ / ជនភៀសខ្លួន (ដែលរួមបញ្ចូលយ៉ាងទូលំទូលាយនូវ អំពើជួញដូរមនុស្ស) និងក្នុងកម្មវិធីសមាហរណកម្មផងដែរ។ នៅពេលដែល UN-ACT ឈានដល់ការបញ្ចប់គម្រោងនៅចុងឆ្នាំ ២០២០ ដូច្នេះទិដ្ឋភាពសំខាន់ៗនៃការងារអាចបន្តនៅក្រោមគម្រោមរបស់ UNDP ដោយមានការគាំទ្រផ្នែកហិរញ្ញវត្ថុពីប្រទេសស៊ុយអែត និងសហភាពអឺរ៉ុប។